# របាយការណ៍
# ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំលើកទី១ របស់គណៈកម្មការតម្រង់ទិសគម្រោង ការគ្រប់គ្រងរួមគ្នា ដើម្បីការពារ និងស្តារសេវាកម្មទីជម្រាល និងប្រព័ន្ធបរិស្ថាននៅតំបន់ជួរភ្នំក្រវាញ (ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត)

## ១. សេចក្តីផ្តើម

គម្រោង "ការគ្រប់គ្រងរួមគ្នា ដើម្បីការពារ និងស្តារសេវាកម្មទីជម្រាល និងប្រព័ន្ធបរិស្ថាននៅតំបន់ជួរភ្នំក្រវាញ (ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត)" ដែលហៅកាត់ថា CoWES ត្រូវបានបង្កើតឡើង ដើម្បីរួមចំណែកកាត់បន្ថយសម្ពាធលើការប្រើប្រាស់ដីធ្លីនៅតំបន់មួយចំនួននៃប៉ែកខាងលើអាងស្ទឹងព្រែកត្នោត តាមរយៈការអនុវត្តបង្ហាញឲ្យឃើញអំពីកិច្ចសហការគ្រប់គ្រងដីកសិកម្ម និងស្តារតំបន់ព្រៃឈើឡើងវិញ រួមជាមួយនឹងការជំរុញការគ្រប់គ្រងដីធ្លីប្រកបដោយចីរភាព និងរក្សាលំនឹងមុខងាររបស់ទីជម្រាលនៅតំបន់រិចរិលមួយចំនួននៃប៉ែកខាងលើអាងស្ទឹងព្រែកត្នោត ក្នុងខេត្តកំពង់ស្ពឺ។ គម្រោងនេះនឹងត្រូវអនុវត្តសម្រាប់រយៈពេល ៣ឆ្នាំ ដែលចាប់ផ្តើមជាផ្លូវការនៅក្នុងខែកក្កដា ឆ្នាំ២០១៧ និងបញ្ចប់នៅក្នុងខែកក្កដា ឆ្នាំ២០២០ ដោយមានការគាំទ្រថវិកាពីទីភ្នាក់ងារសម្របសម្រួលបរិស្ថានពិភពលោក (GEF) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។ កិច្ចប្រជុំលើកទី១ របស់គណៈកម្មការតម្រង់ទិសគម្រោងខាងលើនេះត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ នៅខេត្តកំពង់ស្ពឺ ក្នុងគោលបំណងពិនិត្យឡើងវិញលើចំណុចសំខាន់ៗរបស់គម្រោង និងពិនិត្យ ពិភាក្សាសម្រេចលើក្របខ័ណ្ឌលទ្ធផល យុទ្ធសាស្ត្រអនុវត្តគម្រោង និងផែនការសកម្មភាពនិងថវិកាឆ្នាំ២០១៨ ព្រមទាំងផែនការសកម្មភាពរយៈពេល៣ឆ្នាំ។ សេចក្តីលម្អិតអំពីសារបាន និងកម្មវិធីនៃកិច្ចប្រជុំនេះមានរៀបរាប់ក្នុងឯកសារ **ឧបសម្ព័ន្ធ១**។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំខាងលើនេះ មានចំនួនសរុប ១៧នាក់ ដែលជាសមាជិក សមាជិកា ឬតំណាងនៃគណៈកម្មការតម្រង់ទិសគម្រោង ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ អ្នកគ្រប់គ្រងកម្មវិធីនៃអង្គការ UNDP ប្រចាំកម្ពុជា ទីប្រឹក្សាគម្រោងជាតិនិងអន្តរជាតិ និងក្រុមការងារគម្រោង។ វត្តមាននៃសមាសភាពចូលរួមដូចមានរៀបរាប់ក្នុងឯកសារ **ឧបសម្ព័ន្ធ២**។

## ២. ដំណើរការកិច្ចប្រជុំ

កិច្ចប្រជុំបានដំណើរការជាលក្ខណៈពិភាក្សាពេញអង្គ ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិត **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានគណៈកម្មការតម្រង់ទិស និងជានាយកគម្រោង។ ជាកិច្ចចាប់ផ្តើមកម្មវិធីប្រជុំ ឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍ស្វាគមន៍សមាជិក សមាជិកា និងបានបញ្ជាក់ថា គម្រោង "ការគ្រប់គ្រងរួមគ្នា ដើម្បីការពារ និងស្តារសេវាកម្មទីជម្រាល និងប្រព័ន្ធបរិស្ថាននៅតំបន់ជួរភ្នំក្រវាញ (ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត)" នេះ ត្រូវបានបើកឲ្យដំណើរការអនុវត្ត តាមរយៈសិក្ខាសាលាផ្តើមអនុវត្តគម្រោង ដែលបានប្រព្រឹត្តទៅនៅខេត្តព្រះសីហនុ កាលពីថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៧។ គម្រោងនេះមានសមាសភាគ ឬលទ្ធផលចំនួន៣ ហើយដែលថវិកាសម្រាប់ចំណាយក្នុងការអនុវត្តសមាសភាគទាំងនេះ គឺទទួលបានពី GEF និង UNDP។ ឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍ផងដែរថា កិច្ចប្រជុំថ្ងៃនេះ គឺជាកិច្ចប្រជុំរបស់គណៈកម្មការតម្រង់ទិសគម្រោង ដោយយោងតាមសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការតម្រង់ទិស លេខ៦៥៣ សសរ.កសក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលកិច្ចប្រជុំនេះមានគោលបំណងពិនិត្យ ពិភាក្សាសម្រេចលើសំណើកែសម្រួលឯកសារគម្រោង ក្របខ័ណ្ឌលទ្ធផល យុទ្ធសាស្ត្រអនុវត្តគម្រោង និងផែនការសកម្មភាពនិងថវិកាឆ្នាំ២០១៨ ព្រមទាំងផែនការសកម្មភាពរយៈពេល៣ឆ្នាំ តាមរយៈបទបង្ហាញរបស់ទីប្រឹក្សាគម្រោងជាតិ និងអន្តរជាតិ។

លោក **Nick Beresford** នាយកកម្មវិធីអភិវឌ្ឍសហប្រជាជាតិប្រចាំកម្ពុជា និងជាសមាជិកគណៈកម្មការតម្រង់ទិសគម្រោង បានមានប្រសាសន៍អបអរសាទរក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានរៀបចំសិក្ខាសាលាផ្តើមអនុវត្តគម្រោងប្រកបដោយជោគជ័យ និងទទួលបានលទ្ធផលល្អគួរឲ្យកត់សម្គាល់ ហើយកិច្ចប្រជុំថ្ងៃនេះនឹងពិភាក្សាឲ្យបានស៊ីជម្រៅលើការកែសម្រួលឯកសារគម្រោង និងការរៀបចំផែនការសកម្មភាពនិងថវិកា ដោយផ្អែកលើហេតុផលថា កម្ពុជាមានវឌ្ឍនភាពរីកចម្រើនយ៉ាងឆាប់រហ័សទាំងផ្នែកសេដ្ឋកិច្ច និងសង្គម និងផ្អែកលើលទ្ធផលនៃការសិក្សានៅតំបន់គោលដៅគម្រោង។ លោកនាយកកម្មវិធីបានមានប្រសាសន៍លើកឡើងផងដែរថា ការអនុវត្តគម្រោងគួរតែ ៖ ១.ធ្វើឲ្យមានភាពពាក់ព័ន្ធច្រើនជាមួយសហគមន៍ព្រៃឈើ សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងដៃគូជាមួយ NGO ដែលមានវត្តមាននៅតំបន់គោលដៅគម្រោង ២.បញ្ចូល និងផ្តោតយកចិត្តទុកដាក់លើស្ត្រី ជនក្រីក្រ និងជនជាតិភាគតិចដូចជាជនជាតិស្អួយ ទៅក្នុងការអនុវត្តគម្រោង ក្នុងន័យចូលរួមសម្រេច Sustainable Development Goals និង ៣.ធ្វើឲ្យមានភាពពាក់ព័ន្ធជាមួយធុរកិច្ចកសិកម្ម ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច កសិឧស្សាហកម្ម ដោយប្រកាន់យកអភិក្រមឈ្នះឈ្នះទាំងអស់គ្នា។ ប្រការទាំងអស់នេះ នាំឲ្យយើងមានសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា គម្រោងសាកល្បងតូចមួយនេះ អាចទៅជាគម្រោងធំ ហើយនឹងផ្តល់ផលប្រយោជន៍ដល់អ្នកពាក់ព័ន្ធទាំងអស់ ក្រោមការដឹកនាំ និងតម្រង់ទិសរបស់គណៈកម្មការតម្រង់ទិស។

## ៣. បទបង្ហាញសំខាន់ៗសម្រាប់ការពិភាក្សា ពិនិត្យសម្រេច

ដើម្បីមានព័ត៌មាន និងទិន្នន័យសម្រាប់ជាមូលដ្ឋានក្នុងការពិភាក្សា និងពិនិត្យសម្រេច អង្គប្រជុំបានលើកយកបទបង្ហាញសំខាន់ចំនួន៣ ដើម្បីបង្ហាញជូនសមាជិក សមាជិកាអង្គប្រជុំ ដែលមានដូចជា ៖

១. បណ្ឌិត **មាស ពិសិដ្ឋ** អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគម្រោង បានបង្ហាញអំពីចំណុចសំខាន់ៗ ក្នុងឯកសារដើម នៃគម្រោង "ការគ្រប់គ្រងរួមគ្នា ដើម្បីការពារ និងស្តារសេវាកម្មទីជម្រាល និងប្រព័ន្ធបរិស្ថាននៅតំបន់ភ្នំក្រវាញ (ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត) - (CoWES)" ដោយផ្តោតលើរយៈពេលនិងថវិកាគម្រោង គោលបំណង យុទ្ធសាស្ត្រនិងរចនាសម្ព័ន្ធអនុវត្ត សមាសភាគនិងលទ្ធផល និងការត្រួតពិនិត្យវាយតម្លៃ។ សេចក្តីលម្អិតនៃបទបង្ហាញមាននៅក្នុងឯកសារ **ឧបសម្ព័ន្ធ៣**។

២. លោក **សំ និស្ស័យ** ទីប្រឹក្សាជាតិសម្រាប់គម្រោង បានបង្ហាញអំពីវឌ្ឍនភាព និងការកសាងផែនការ ដែលក្នុងនោះ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពរបស់គម្រោងមួយរយៈកន្លងមកនេះ មានដូចជា ៖ ការសិក្សាអំពីស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋនៅតំបន់គោលដៅគម្រោង ការផ្សព្វផ្សាយនិងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធអំពីទស្សនទានគម្រោង ការបង្កើតគណៈកម្មការតម្រង់ទិសគម្រោង ការរៀបចំសិក្ខាសាលាផ្តើមអនុវត្តគម្រោង និងការធ្វើលទ្ធកម្មជាដើម។ល។ ដោយឡែកការកសាងផែនការ គឺបានបង្ហាញអំពីការរៀបចំផែនការសកម្មភាពនិងថវិកា និងតម្រូវការទីប្រឹក្សាសម្រាប់ឆ្នាំ២០១៨ ព្រមទាំងការកសាងផែនការសកម្មភាពសម្រាប់រយៈពេល៣ឆ្នាំ ជាមួយនឹងការវិភាជន៍ថវិកាតាមបណ្តាឆ្នាំនីមួយៗផងដែរ។ សេចក្តីលម្អិតនៃបទបង្ហាញមានក្នុងឯកសារ **ឧបសម្ព័ន្ធ៤**។

៣. លោក **Ed Queblatin** អ្នកជំនាញការរបស់អង្គការ UNDP បានធ្វើបទបង្ហាញស្តីពីសំណើកែសម្រួលឯកសារគម្រោង ក្របខ័ណ្ឌលទ្ធផល និងយុទ្ធសាស្ត្រអនុវត្តគម្រោង រួមជាមួយនឹងការបញ្ជាក់អំពីហេតុផលមួយចំនួនទាក់ទងនឹងការស្នើកែសម្រួលនេះ។ ទន្ទឹមនឹងនេះដែរ លោកជំនាញការបានស្នើឲ្យមានគណៈកម្មការប្រឹក្សាបច្ចេកទេស (Technical Advisory Committee) និងស្នើបន្ថែមសូចនាករមួយចំនួនសម្រាប់លទ្ធផលទាំង៣ របស់គម្រោង។ សេចក្តីលម្អិតនៃបទបង្ហាញមានក្នុងឯកសារ **ឧបសម្ព័ន្ធ៥**។

## ៤. កិច្ចពិភាក្សាពេញអង្គ

អង្គប្រជុំបានកត់ត្រានូវបទបង្ហាញទាំង៣ ខាងលើ និងបានលើកឡើងនូវបញ្ហាពាក់ព័ន្ធមួយចំនួនដូចខាងក្រោម ៖

- ឯកភាពលើការកែសម្រួលឯកសារគម្រោង និងស្នើឲ្យមានការជំរុញការចូលរួមរបស់ស្ត្រីទាំងក្នុងការងារកសិកម្ម និងសហគមន៍ព្រៃឈើ ព្រោះថា ៖ នៅក្នុងសហគមន៍ ភូមិ ឬឃុំ ចំនួនស្ត្រីច្រើនជាងបុរស។ ផែនការ

សកម្មភាពឆ្នាំ២០១៨ ហាក់ដូចជាច្រើនពេក អាចអនុវត្តមិនទាន់ពេល ដូចនេះ គួរមានក្របខ័ណ្ឌពេលវេលា (Timeframe) និងស្ថាប័នទទួលខុសត្រូវសម្រាប់សកម្មភាពនីមួយៗ។

- គួរឲ្យមានការចូលរួមរបស់ប្រជាជនឲ្យបានច្រើនក្នុងការអនុវត្តគម្រោង។ នៅក្នុងគណៈកម្មការតម្រង់ទិស គួរបញ្ចូលបន្ថែមតំណាងមន្ទីរធនធានទឹក មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ និងសាកលវិទ្យាល័យភូមិន្ទកសិកម្មផងដែរ។
- គួរមានទិន្នន័យអំពី Gender មុខរបរ និងស្ថានភាពសេដ្ឋកិច្ច មុនចាប់ផ្តើមអនុវត្តគម្រោង ដោយសារ នៅទីជនបទស្ត្រីភាគច្រើនធ្វើកសិកម្ម និងប្រកបមុខរបរសម្រាប់គ្រួសារ ដោយធ្វើការកត់ត្រាចំនួនស្ត្រី និងបុរស ទាំងអ្នកចូលរួម និងទទួលផល។ គួរធ្វើការអប់រំស្ត្រីឲ្យចេះផលិត ហើយចេះធ្វើម្ហូបអាហារប្រកបដោយសុវត្ថិភាព និងមានអាហារូបត្ថម្ភសំបូរបែប ដោយធ្វើការពង្រឹងជំនាញ របស់ស្ត្រីដែលមាន ហើយគួរធ្វើការសហការជាមួយបណ្តាញ Gender ដែលមាននៅថ្នាក់ខេត្ត និងស្រុក។
- ត្រូវមានប្រព័ន្ធ M&E ឲ្យហើយ នៅពេលចាប់ផ្តើមអនុវត្តគម្រោង ក្នុងន័យធ្វើឲ្យគម្រោងសាកល្បងតូចនេះមានអំណះអំណាងអំពីលទ្ធផលសម្រេចបានជោគជ័យ ដើម្បីទាក់ទាញភ្នែកអ្នកផ្តល់ជំនួយក្នុងការបន្តផ្តល់ធនធានសម្រាប់ពង្រីកការអនុវត្តសកម្មភាពគម្រោង។ គួររៀបចំផ្តល់ការឆ្លើយតបទៅ GEF ឲ្យបានឆាប់អំពីការស្នើកែសម្រួលឯកសារគម្រោងនេះ។ អង្គការ UNDP ត្រៀមខ្លួនជាស្រេចក្នុងការផ្តល់ជំនួយបច្ចេកទេស (ធនធានបន្ថែម) សម្រាប់ការសិក្សាវាយតម្លៃបរិស្ថាន និងសេដ្ឋកិច្ចដោយអ្នកជំនាញអន្តរជាតិ។
- គាំទ្រចំពោះការជ្រើសរើសយក Micro-watershed នៅក្នុងឃុំចំនួន២ និងបន្ថែមយកឃុំទាំង៣ គឺឃុំត្រពាំងជោរ ឃុំតាសាល និងឃុំក្រាំងដីវ៉ាយ ដែលនៅប៉ែកខាងលើទីជម្រាលស្ទឹងព្រែកត្នោត។ ចំពោះការជ្រើសរើសឃុំ តាសាលបន្ថែមនេះ ក្នុងគោលបំណងចង់ឃើញអំពីការផ្លាស់ប្តូរឥរិយាបទ ឬទម្លាប់ពីការរកស៊ីកាប់ឈើធ្វើធ្យូង ទៅជាការប្រកបរបរកសិកម្មចម្រុះមាននិរន្តរភាព។ ការជ្រើសរើសទីតាំងនេះ គឺត្រូវគិតអំពីឆន្ទៈចង់ធ្វើមានទឹកចិត្តចូលរួមធ្វើរបស់ ប្រជាជន ដោយធ្វើយ៉ាងណាឲ្យមានការស្តារព្រៃ និងការបង្កើនផលិតភាព ទិន្នផលកសិកម្ម និងផលប្រយោជន៍ ជាក់ស្តែងសម្រាប់ប្រជាជនដែលនៅផ្នែកខាងលើទីជម្រាលនេះ ជាមុនសិន។ អ្នកជំនាញការ និងទីប្រឹក្សា គួរចាប់ផ្តើមណែនាំអំពី Smart Agriculture or Conservation Agriculture ព្រមទាំងរៀបចំបង្កើតឲ្យមាន Integrated water and land use planning នៅក្នុងឃុំទាំង៣ ជាមុនសិន។
- គម្រោងសាកល្បងនេះ គឺអនុវត្តខ្លឹមសារសំខាន់ៗ ដែលមាននៅក្នុង NAP។ ដូចនេះ ត្រូវមានការប្រឹងប្រែងអនុវត្តឲ្យអស់លទ្ធភាព ដើម្បីទទួលបានជោគជ័យ ក្នុងន័យផ្តល់មេរៀនសម្រាប់អនុវត្តនៅថ្ងៃខាងមុខ។ ទីប្រឹក្សាជាតិ អន្តរជាតិត្រូវធ្វើឲ្យប្រាកដថា ជួយខ្មែរឲ្យចេះធ្វើពិតប្រាកដ ឲ្យយល់និងចេះធ្វើបាន។ កិច្ចប្រជុំរបស់គណៈកម្មការតម្រង់ទិសលើកក្រោយ គួរធ្វើនៅស្រុកគោលដៅ ដែល ធ្វើឲ្យសមាជិក សមាជិកាគណៈកម្មការអាចពិនិត្យស្ថានភាព និងសកម្មភាពគម្រោងនៅក្នុងស្រុកគោលដៅ។ គួរវិភាជថវិកាគម្រោង ដើម្បីគាំទ្រដល់ការបញ្ចប់ NAP។
- គួរពន្យាពេលអនុវត្តគម្រោងដល់ចុងឆ្នាំ២០២០ ដោយសារមានការយឺតយ៉ាវក្នុងការចាប់ផ្តើមអនុវត្តគម្រោង។
- ដើម្បីនិរន្តរភាព និងប្រសិទ្ធភាពនៃគម្រោង គួរមានការបញ្ជ្រាបទស្សនទានគម្រោងនេះ និងធ្វើការវិភាជន៍ថវិកាព្រមទាំងរៀបចំផែនការសកម្មភាពតាមឆ្នាំ សម្រាប់ធ្វើសមាហរណកម្មជាមួយផែនការអភិវឌ្ឍឃុំ ក្នុងន័យឲ្យមូលដ្ឋានយល់ និងដឹកនាំប្រជាជនអនុវត្ត។
- នីតិវិធីក្នុងភាពជាដៃគូជាមួយស្ថាប័នពាក់ព័ន្ធ រួមមានអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាល គឺធ្វើតាមរយៈកិច្ចព្រមព្រៀងជាមួយស្ថាប័ននោះ ដោយរៀបចំផែនការសកម្មភាព និងថវិកា ឬលក្ខខ័ណ្ឌការងារ (TOR) បន្ទាប់មកចុះកិច្ចសន្យាអនុវត្ត។

## ៥. សេចក្តីសម្រេចរបស់អង្គប្រជុំ

ជាមួយនឹងការប្រកាសបិទកិច្ចប្រជុំ ឯកឧត្តម បណ្ឌិត **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មការតម្រង់ទិសគម្រោង បានមានប្រសាសន៍បូកសរុបការសម្រេចរបស់អង្គប្រជុំលើចំណុចមួយចំនួនដូចខាងក្រោម ៖

- ឯកភាពជារួមលើសំណើកែសម្រួលឯកសារគម្រោង ក្របខ័ណ្ឌលទ្ធផល សមាសភាគទាំង៣ របស់គម្រោង លទ្ធផលរំពឹងទុកចំនួន៧ សូចនាករលទ្ធផលរំពឹងទុក យុទ្ធសាស្ត្រអនុវត្តគម្រោង និងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨ រួមមានផែនការលទ្ធកម្មទីប្រឹក្សា ការជ្រើសបុគ្គលិកពេញម៉ោងសម្រាប់គម្រោង និង កិច្ចសន្យាជាមួយអង្គការមិនមែនរដ្ឋាភិបាល និងនាយកដ្ឋានជំនាញ ព្រមទាំងផែនការសកម្មភាពសម្រាប់ រយៈពេល៣ឆ្នាំ ដូចមានរៀបរាប់លម្អិតក្នុងឯកសារ ឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ ដែលក្នុងនោះ ស្នើឲ្យមាន ការរៀបចំបន្ថែមនូវសកម្មភាពលម្អិត ដោយមានបញ្ជាក់អំពីក្របខ័ណ្ឌពេលវេលា (Timeframe) ដែលនឹង ត្រូវអនុវត្តសកម្មភាពទាំងនោះ។
- សម្រេចបញ្ចូលសមាសភាពពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ និងសាកលវិទ្យាល័យភូមិន្ទ កសិកម្ម បន្ថែមនៅក្នុងគណៈកម្មការតម្រង់ទិសគម្រោង។
- ឯកភាពថា កិច្ចប្រជុំគណៈកម្មការតម្រង់ទិសគម្រោងលើកក្រោយ គឺប្រារព្ធធ្វើនៅក្នុងស្រុកគោលដៅគម្រោង ដើម្បីផ្តល់ឱកាសឲ្យសមាជិក សមាជិកាគណៈកម្មការ ជួបជាមួយសហគមន៍មូលដ្ឋាន និងពិនិត្យសកម្មភាព គម្រោងនៅលើទីតាំងជាក់ស្តែង។
- សម្រេចរៀបចំវិភាជថវិកា និងផែនការសកម្មភាពគម្រោងលម្អិតរយៈពេល៣ឆ្នាំ ដើម្បីធ្វើសមាហរណកម្ម ជាមួយផែនការអភិវឌ្ឍឃុំទាំង៣ របស់គម្រោង ព្រមទាំងវិភាជថវិកាសម្រាប់គាំទ្របញ្ជប់ NAP។
- សម្រេចលើការបញ្ចូលស្ត្រីឲ្យបានច្រើន (គិតពិចារណាអំពី Gender ក្នុងការអនុវត្តគម្រោង) នៅក្នុងការ អនុវត្តសកម្មភាពគម្រោង ដោយធ្វើការសិក្សាផងដែរអំពីឥទ្ធិពល (Impact) របស់គម្រោងទៅលើជីវភាព របស់ស្ត្រីចូលរួមក្នុងគម្រោង និងមិនបានចូលរួមក្នុងគម្រោង។
- ឯកភាពជាគោលការណ៍លើការពន្យាពេលអនុវត្តគម្រោងរហូតដល់ចុងឆ្នាំ២០២០ ប៉ុន្តែត្រូវរង់ចាំពិនិត្យ ជាក់ស្តែងនៅក្នុងកិច្ចប្រជុំគណៈកម្មការតម្រង់ទិសគម្រោងនៅឆ្នាំ២០១៩។
- ឯកភាពថា មិនចាំបាច់មានគណៈកម្មការប្រឹក្សាបច្ចេកទេសនៅក្នុងរចនាសម្ព័ន្ធអនុវត្តគម្រោងតាមការស្នើ ឡើងរបស់ទីប្រឹក្សាគម្រោងទេ គឺមានត្រឹមតែកម្រិតមន្ត្រីបង្គោល (Focal Point) នៅតាមអង្គភាពជំនាញ ពាក់ព័ន្ធគ្រប់គ្រាន់ហើយ។

ថ្ងៃព្រហស្បតិ៍៧រោចខែមាឃ ឆ្នាំរកា នពស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨

អ្នកធ្វើរបាយការណ៍

ញ៉ាន រតនា

**បានឃើញ និងឯកភាព**

**ឯកឧត្តម បណ្ឌិត ទី សុគន្ធ**
**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការតម្រង់ទិស**